# សិលាចារឹកថ្មីមកពីស្រុកអន្លង់វែង K.១៤៦៧[១]

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ លោក **ឡុង ងិល** បានរកឃើញសិលាចារឹកមួយផ្ទាំង នាពេលបើកត្រាក់ទ័រ ដើម្បីពូនរងដាំដំឡូងមីនាចម្ការរបស់លោក **យ៉ា ប៊ុន** ស្ថិតនៅក្នុងភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ លោក **យាន យ៉ា** មន្ត្រីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ បានបញ្ជាក់ថានៅក្នុងបរិវេណចម្ការដែលរកឃើញសិលាចារឹកនេះ ជាទីតាំងបុរាណដ្ឋានដែលមានទួលប្រាសាទឥដ្ឋផង។ បន្ទាប់មក នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៨ លោក **យ៉ា ប៊ុន** ក៏បានប្រគល់សិលាចារឹកនេះ ជូនអាជ្ញាធរពាក់ព័ន្ធ ដើម្បីយកទៅរក្សាទុកនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្ត។

សិលាចារឹកនេះសាងអំពីថ្មភក់ព័ណ៌ផ្កាឈូក រចនារាងជាបង្គោលសីមា មានកម្ពស់ ១០៣ស.ម. បន្ទាស៤០.០៥ស.ម. និងកម្រាស់២១ស.ម.។ ផ្នែកខាងក្រោមរចនាជាពន្លួញសម្រាប់តម្កល់សិលាចារឹកនេះនៅលើជើងទម្រ ប៉ុន្តែគេរកពុំទាន់ឃើញជើងទម្រនេះនៅឡើយទេ។ អត្ថបទចារឹកមានចំនួនមួយផ្ទាំង សរសេរជាអក្សរនិងភាសាខ្មែរសម័យអង្គរ ចំនួន១៧បន្ទាត់ និងដាច់បាត់កាលបរិច្ឆេទ ដោយផ្ទាំងថ្មផ្នែកឆ្វេង បានបែកដោយអន្ទើ ជាពិសេសនៅផ្នែកខាងលើពីបន្ទាត់ទី១ដល់ទី៥ ។ យ៉ាងនេះក្តី ដោយផ្អែកលើអក្ខរក្រម និងស្ថាននាម មានលក្ខណៈស្របគ្នានឹងសិលាចារឹកបន្ទាយស្រី K.៥៧០ និង K.៥៧១ យើងអាចកំណត់បានថា សិលាចារឹកនេះ ស្ថិតនៅក្នុងពាក់កណ្តាលទី២ នៃស.វ.ទី១០ ក្នុងរាជ្យព្រះបាទជ័យវម៌្មទី៥ (៩៦៨-១០០១)។

អត្ថបទសិលាចារឹកនេះចាប់ផ្តើមដោយបង្ហាញពីព្រះមហាក្សត្រ បានប្រទានដីភូមិបីកន្លែងដល់ព្រះគ្រូ ដែលលោកបានស្ថាបនាប្រាសាទ(បន្ទាយស្រី)និងធ្វើបុណ្យចំពោះព្រះ

---

[១] ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក **ហុង យឿង** ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ដែលបានអនុញ្ញាតឱ្យខ្ញុំបានចុះផ្តិតសំណៅសិលាចារឹក នៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោក **អន ផល្លា** លោក **នីម ម៉ាន់ជេ** និងលោក **យាន យ៉ា** ជាមន្ត្រីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តឧត្តរមានជ័យ ដែលមានជួយជ្រោមជ្រែង សម្របសម្រួលផ្តល់ព័ត៌មាន និងជូនទៅកាន់ទីតាំងបុរាណដ្ឋានមានសិលាចារឹកនានាក្នុងខេត្តឧត្តរមានជ័យ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

គម្តែងអញស្រីត្រីភូវនមហេសូរ នៅឥសូរបូរ។[២] ដីចង្វាត់[៣]បីកន្លែងនោះមានឈ្មោះថាភូមិព្រៃទម្រោ ស្រែភ្ញើង និងវហាព្រីង។ អត្ថបទបន្ទាប់ជាការកំណត់ព្រំប្រទល់ដីទាំងបីកន្លែងនោះ។ នៅខាងចុងអត្ថបទជាការបញ្ជាក់ថាដីចង្វាត់ទាំងបីកន្លែងនោះ មិនស្ថិតក្រោម (ការគ្រប់គ្រងរបស់) ស្តេងអញព្រះគ្រូព្រេងប្រាសនិងវាបសិខាពិន្ទុឡើយ។

ដោយសារកត្តាទម្រង់តួអក្សរក្នុងសិលាចារឹកនេះ ទេវនាម និងស្ថាននាម លោកបណ្ឌិត **វង់ សុធារ៉ា** បានសន្និដ្ឋានជាបឋមថាសិលាចារឹកនេះ ប្រហែលមានការផ្លាស់ទី (ដោយការលួចឬជួញដូរ)ពីតំបន់ក្បែរប្រាសាទបន្ទាយស្រី ក្នុងបំណងនាំចេញទៅលក់ប្រទេសថៃ។[៤] ចំណុចនេះ យើងត្រូវពិនិត្យពិចារណាទៅលើតឹកតាងនានា ដើម្បីបង្ហាញថាតើសិលាចារឹកនេះ ពិតជាបានផ្លាស់ទីពីទីតាំងណាមួយក្បែរប្រាសាទបន្ទាយស្រី ឬមានទីតាំងដើមនៅតំបន់ដែលរកឃើញសិលាចារឹកនេះផ្ទាល់តែម្តង។

នៅក្នុងសិលាចារឹកប្រាសាទបន្ទាយស្រី K.៨៧១ បានចារឹកឃ្លាថា «(១)๏បរិគ្រហតម្រតេញ៑កុលបតី·វ្រះអន្រាយិទម្រោ[៥]អ្នក៑បំរេម្វាយ(២)ស្រូកែម្វាយិតប្ប·មោក៑ព្ល៑គ្វរបុររង្គោរកែ

---

[២] នៅក្នុងសិលាចារឹកនេះ ពុំមានបញ្ជាក់អំពីឈ្មោះរបស់ព្រះគ្រូនោះឡើយ ប៉ុន្តែតាមសេចក្តីដែលបង្ហាញថាលោកគឺជាអ្នកស្ថាបនានិងធ្វើបុណ្យថ្វាយចំពោះព្រះស្រីត្រីភុវនមហេសូរនោះ គឺទំនងជាសំដៅដល់ព្រះគ្រូយជ្ញវរាហ ដែលជាព្រះរាជគ្រូមួយអង្គរបស់ព្រះបាទជ័យវម៌្មទេវទី៥។ ចំពោះ «ស្រីត្រីភុវនមហេសូរ» គឺជាព្រះសិវលិង្គតម្កល់នៅប្រាង្គកណ្តាលនៃប្រាសាទបន្ទាយស្រី។ ចំណែកឯ «ឥសូរបូរ» គឺជាឈ្មោះប្រាសាទបន្ទាយស្រីពីបុរាណ មានន័យថាទីក្រុងព្រះឥសូរ។

[៣] ចង្វាត់ < ធ្វាត់ < វាត់ គឺ សំដៅដល់ព្រំប្រទល់ដីដែលធ្វាត់ឬធ្វូតជាប្លង់។ ពាក្យ «ចង្វាត់» នេះ សៀមយកទៅប្រើជា «จังหวัด» សម្គាល់ខេត្តក្នុងប្រទេសថៃនាពេលបច្ចុប្បន្ន។

[៤] សូមអាន៖ https://www.phnompenhpost.com/national/farmer-discovers-mystery-stone-tablet-anlong-veng និង https://web.facebook.com/129980634394216/posts/190567711668841/?_rdc=1&_rdr។

[៥] នៅក្នុងសិលាចារឹកសរសេរជា «អគ្រាយិងម្រោ» យើងយល់ថាជាការច្រលំរបស់អ្នកចារ ដែលពាក្យត្រឹមត្រូវគឺជា «អន្រាយិទម្រោ» ដែលត្រូវគ្នានឹងសិលាចារឹកនេះ។ ម្យ៉ាងទៀត យើងយល់ថាស្ថាននាម «ព្រៃទម្រោ» ក្នុងសិលាចារឹកនេះ និង «ទម្រោ» នៅសិលាចារឹកប្រាសាទបន្ទាយស្រី K.៨៧១ ជាស្ថាននាមតែមួយ ដ្បិតសិលាចារឹកថ្មីមួយទៀតដែលរកឃើញនៅក្នុងភូមិរំចេក ឃុំអន្លង់វែង ដែលមានរូបរាង និងសាច់រឿងដូចគ្នានឹងសិលាចារឹកនេះដែរនោះ គឺប្រើត្រឹមតែឈ្មោះ «ទម្រោ» ប៉ុណ្ណោះ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

*វ្យរ· --- (៦)----·វ្រះអទ្រាយ៑ស្រេវ្វេង៑រង្កោថ្ងង៑(៧)ប្រម្វាយ៑·មោក៑ព្ល៝ត្វរបុរឃ្ងូដ[៦]អន្តង៑វ្យរ·» មានសេចក្តីសម្រួលជាភាសាខ្មែរទំនើបថា «បរិគ្រោះ(ផ្តល់ឱ្យ)ដល់ម្រតេញកុលបតី (មាន)ព្រះអទ្រាយទម្រោ(នូវ)អ្នកបម្រើម្នាក់ ស្រូវ៣០ (ផ្តល់ឱ្យ)មកឥសូរបូរអង្ករ៤០។---។ ព្រះអទ្រាយស្រែភ្លើង(នូវ)អង្ករ៦ត្លោង (ផ្តល់ឱ្យ)មកឥសូរបូរ(នូវ)ប៊ិរទឹកដោះគោ២អណ្តូង។»។ នៅត្រង់ចំណុចនេះ យើងឃើញថាដីទម្រោនិងស្រែភ្លើងពុំស្ថិតនៅក្នុងឥសូរបូរទេ ប៉ុន្តែទំនងជាចំណុះឱ្យឥសូរបូរ។ ចំណែកឯសិលាចារឹក K.១៤៦៧ នេះ ក៏ពុំបានបញ្ជាក់ថាដីទាំងបីកន្លែងនោះស្ថិតនៅក្នុងទឹកដីឥសូរបូរដែរ ប៉ុន្តែដីភូមិទម្រោមានព្រំប្រទល់ជាប់នឹងឥសូរបូរ។ ដីទាំងនេះមិនអាចស្ថិតនៅឆ្ងាយពេកពីតំបន់ប្រាសាទបន្ទាយស្រីនោះឡើយ។*

*តាមការបង្ហាញពីលោក **យាន យ៉ា** គឺមានសិលាចារឹកថ្មីមួយទៀត រកឃើញនៅភូមិរំចេក ឃុំអន្លង់វែង ដូចគ្នា ត្រូវអ្នកស្រុករក្សាទុកនៅក្នុងខ្ទមអ្នកតា។ ក្រៅពីមានរូបរាងស្រដៀងគ្នា សិលាចារឹករកឃើញថ្មីនេះ ក៏មាននិយាយអំពីរឿងដីទម្រោនិងរហាព្រីង[៧]ដូចសិលាចារឹក K.១៤៦៧ ផងដែរ។ លោកបញ្ជាក់បន្ថែមផងដែរថា នៅស្រុកអន្លង់វែងមានគ្រឹះប្រាសាទជាច្រើន ប៉ុន្តែពុំសូវមានសំណល់សម្ភារៈសំណង់ប្រាសាទច្រើននោះទេ។ កត្តានេះយើងអាចយល់បានថាទំនងជាមានការជួញដូរវត្ថុទាំងនោះ នាកាលកន្លងមក។ ការជួយដូរវត្ថុបុរាណ នាំឱ្យមានការកែប្រែនិងផ្លាស់ប្តូររូបរាងបុរាណដ្ឋាន តាមរយៈការជីកគាស់កាយនាពេលកន្លងមក បានបំផ្លាញតឹកតាងប្រវត្តិសាស្ត្រ បុរាណវិទ្យាជាដើម ដែលជាព័ត៌មានយ៉ាងសំខាន់សម្រាប់ការសិក្សាពីអតីតកាល។*

*ទីតាំងដើមនៃសិលាចារឹកទាំងពីរនេះ នៅតែជាមន្ទិលដែលពុំទាន់អាចស្រាយបានច្បាស់លាស់នៅឡើយ ដែលទាមទារឱ្យមានការស្រាវជ្រាវពិនិត្យផ្ទៀងផ្ទាត់បន្ថែមទៀតរវាងទីតាំងក្បែរប្រាសាទបន្ទាយស្រី និងទីតាំងបុរាណដ្ឋាននានានៅក្នុងស្រុកអន្លង់វែង។*

---

*[៦] នៅក្នុងសិលាចារឹកសរសេរជា «ឃ្ងូង» ជាការភាន់ច្រឡំរបស់អ្នកចារ ដែលពាក្យត្រឹមត្រូវគឺ «ឃ្ងូដ»។*

*[៧] ដោយសាររូបភាពសិលាចារឹកដែលទទួលបានមានគុណភាពពុំសូវច្បាស់ ទើបធ្វើឱ្យយើងមិនអាចអានអត្ថបទបានទាំងស្រុង។ យ៉ាងនេះក្តីតាមទម្រង់អក្សរនិងស្លាននាមដែលលេចឡើង សិលាចារឹកនោះគួរតែជាអត្ថបទតឬអត្ថបទដែលនិយាយអំពីព្រំប្រទល់ដីទាំងបីកន្លែងនេះដដែល។*

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*

## អត្ថបទដើមជាអក្សរខ្មែរទំនើប

១- ------(គ)ក(នុ)មានវ្រះគាសនធូលិវ្រះបាទធូលិជេង៑

២- [[វ្រះកម្រតេង៑អញ]](ឱ)យ៑វ្រះករុណាប្រសាទភូមិវ្រៃទម្រោស្រេវេ្ង៑

៣- [[នុហ៑ាវ្យេង៑ត]]វ្រះគុរុនាស្ថាបនាថ្វេធម៌្មបិឱយ្ដវ្រះកម្រតេង៑អ

៤- [[ញ៑ស្រីត្រិកុវនម]]ហេតុវអោយ៑ព្ល៌ុគ្នបុរ•ចង្វាតិភូមិទម្រោ•តោយ៑បូវ៌្វ

៥- ----[[•]](តោ)យ៑បូវ៌្វ•តោយ៑ទក្សិណល្ហោះសរិត៑[៨]កន្តាលវ្រះវ្រៃយ•តោ

៦- [យ៑]បឝ្ចិមប្រសប៑ភូមិស្រេវេង៑•តោយ៑ឧត្តរ•តំបាល៑•នេះគិអំបាល្ភូមិ

៧- (កំ)លុង្វចង្វាតិនោះ•ថ្វោង៑រាង៑អន្វេ៣•តោង៑ក្រណី•ទក្កល៑ឥត៑•ប្ញ•វនិ

៨- -ក៑•ជទ្រំ•ធម៌្មគ្រាម•ប្រសប៑ភូមិវ្រះកម្រតេង៑អញគិវបុរ៙ច

៩- [ង្វា]តិភូមិស្រេវេង៑•តោយ៑បូវ៌្វប្រសប៑ទម្រោ•តោយ៑ទក្សិណកន្តាល

១០- វ្រះវ្រៃ•តោយ៑បឝ្ចិមប្រសប៑ហ៑ាវ្យេង៑•តោយ៑វាយវ្យ•ថ្គារ៑•តោយ៑ឧត្តរ

១១- ល្ហោះតគោល៑ជនាទ៌ណ•តោយ៑ព្ល៌ុគានប្រសប៑ទម្រោ•នេះគិអំបាល្ភូ

១២- (មិ)កំលុង្វចង្វាតិនោះ•លិំក្រកុប៑•ស្នាល៑កន្វះហ•ឱក៑(រ)ង្កោកន្វះហ•(កំ)

១៣- (វ)ង៑តម្រ្យអន្វេ៣•ជ្វ៌យ៑•បាទនាទិ•បាក៑ខ្លាល៑•ទិ(ក្តោរ)ធៅកន្តាល្តុំ(•)

១៤- (ច)ង្វាតិភូមិហ៑ាវ្យេង៑•តោយ៑បូវ៌្វប្រសប៑ស្រេវេង៑•តោយ៑ទក្សិណលិំក

១៥- (ន្តា)ល៑វ្រះវ្រៃ•តោយ៑បឝ្ចិម•កន្សុត៑•តោយ៑ឧត្តរប្រសប៑(តំ)បុំ•ភូមិកំ

១៦- (លុង៑)ចង្វាត៑•លិំ(មា)ស៑•ភូមិកំលុង្វចង្វាតិតវ៌ទៅតស្តេង៑អញវ្រះគុ

១៧- [រុ]វ្រេង៑(ប្រា)ស៑[នុ]វាប៑គិខារិន្ទុ/៙/

## អត្ថបទសម្រួលជាភាសាខ្មែរទំនើប

(១-៤) (មហាសករាជឆ្នាំ---) មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះកម្ដែងអញប្រទានដីភូមិព្រៃទម្រោ ស្រែភ្ញើង និងវហាព្រីងដល់ព្រះគ្រូនាពេល(លោក)ស្ថាបនា និងធ្វើបុណ្យថ្វាយចំពោះព្រះកម្ដែងស្រីត្រីភុវនមហេសូរ។

(៤-៨) ចង្វាត់(ព្រំប្រទល់)ដីភូមិទម្រោ ខាងកើត(នៅ)--- ខាងត្បូងរហូតដល់សំរិតកណ្ដាលព្រះព្រៃ ខាងលិចប្រសព្វដីភូមិស្រែភ្ញើង ខាងជើង(នៅ)តំបាល។ នេះគឺដីភូមិទាំង

[៨] ពាក្យត្រឹមត្រូវទំនងជា «សំរិត៑» ?

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ឡាយដែលនៅក្នុងចង្វាត់នោះ (គឺដី)ថ្លោងរាង(ចំនួន/ទំហំ)៣អន្ទើ តោងក្រណី ទក្កលឥត ប្រ៊ី[៩] វន-ក ជទ្រំ ធម្មគ្រាម (ទៅ)ប្រសព្វនឹងដីភូមិព្រះគម្តែងអញសិវបូរ។

(៨-១៣) ចង្វាត់(ព្រំប្រទល់)ដីដីភូមិស្រែភ្ញើង ខាងកើតប្រសព្វទម្រោ ខាងត្បូង(នៅ) កណ្តាលព្រះព្រៃ ខាងលិចប្រសព្វរហាព្រើង ខាងពាយ័ព្យ(នៅ)ថ្គារ ខាងជើងរហូតដល់គោលជនាទ្ទំណា[១០] ខាងឥសានប្រសព្វទម្រោ។ នេះគឺដីភូមិទាំងឡាយដែលនៅក្នុងចង្វាត់នោះ (គឺដី)រលំក្រខុប ស្តួល[១១](ទំហំ)ពាក់កណ្តាល ឱកអង្គរ(ទំហំ)ពាក់កណ្តាល កំពង់ដំរី[១២](ចំនួន/ទំហំ)៣អន្ទើ រជួយ បាទនាទី បាក់ក្អួល ទីត្តោរនៅកណ្តោលជុំ។

(១៤-១៦) ចង្វាត់ដីភូមិរហាព្រើង ខាងកើតប្រសព្វស្រែភ្ញើង ខាងត្បូង(នៅ)កណ្តាលព្រះព្រៃ ខាងលិច(នៅ)កន្សុត ខាងជើងប្រសព្វតំបុំ។ ដីភូមិនៅក្នុងចង្វាត់(នោះគឺ)រលំមាស។

(១៦-១៧) ដីភូមិនៅក្នុងចង្វាត់ពុំស្ថិតក្រោម(ការគ្រប់គ្រងរបស់)ស្តែងអញព្រះគ្រូព្រេងប្រាសនិងវាបសិខាពិន្ទុ(ឡើយ)។

## ឯកសារយោង


Finot, L., Parmentier, H., & Goloubew, V.

( 1926 ). *Temple d'Içvarapura ( Bantāy Srĕi, Cambodge )*. G. Vanoest.

Pou, Saveros.

( 2001 ). *Nouvelles inscriptions du Cambodge, II & III.* EFEO.


---

[៩] «ប្រ៊ី» ជារុក្ខជាតិដុះក្នុងទឹកពពួក គេអាចយកដើមក្រងប្រក់ផ្ទះឬគាបធ្វើជញ្ជាំងបាន។ «ប្រ៊ី» បានក្លាយជាធាតុមួយនៃស្ថាននាម ដែលបច្ចុប្បន្នគេយល់ច្រឡំនឹងពាក្យ «ប្រិយ» ដែលមកពីសំស្ក្រឹតទៅវិញ។ ស្ថាននាម «ប្រ៊ី» (បុរាណសរសេរជា «ប្វ») នេះ ប្រទះក្នុងសិលាចារឹករកឃើញនៅក្នុងខេត្តកំពង់ធំនិងសៀមរាបដូចជា K.១៥៨ខ៖ ប.១៦, ប.៣១ & ប.៣២; K.១៥៨យ៖ ប.៨; K.១៧៥លិច៖ ប.៣។

[១០] «ជនាទ្ទំណា» ជាស្ថាននាមដែលលេចឡើងនៅក្នុងសិលាចារឹក K.៩១ខ៖ ប.១៣; K.២០៧ត្បូង៖ ប.៤៣; K.២០៨: ប.៦៥; K.៣៧៤: ប.២០។

[១១] ស្ថាននាមនេះជួបប្រទះពីរដងក្នុងសិលាចារឹកស្តុកកក់ធំ K.២៣៥យ៖ ប.៨៩ និងសិលាចារឹកគុកអង្គាញ់ K.៨៤៤៖ ប.៨។

[១២] ស្ថាននាមនេះជួបប្រទះក្នុងសិលាចារឹកភ្នំដី K.៤៥៧៖ ប.៩។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

# បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹកK.១៤៦៧ ដោយ ហ៊ុន ឈុនតេង

អត្ថបទដោយៈ ហ៊ុន ឈុនតេង